**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៤៤៧/៥៣១ ប្រក.កសក.សហវ

# ប្រកាសរួម
# ស្តីពី
# តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើ ដើម្បីពិន័យអន្តរការណ៍

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និង
## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យទាំងឡាយដែលតម្លើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុក្រឹត្យទាំងឡាយដែលតម្លើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញការចាំបាច់

# សម្រេច

**ប្រការ ១ :** ត្រូវបានកំណត់ឱ្យប្រើប្រាស់នូវតម្លៃទីផ្សារជាមូលដ្ឋាននៃឈើជ្រុង ឈើអារ តាមបណ្តារាជធានី ខេត្ត ដើម្បីពិន័យអន្តរការណ៍ នៅទូទាំងប្រទេសដូចក្នុងតារាងខាងក្រោម :

( គិតជារៀល/ម[៣] )

| ល.រ | ខេត្ត | ឈើប្រណិត | | | | | ឈើ លេខ១ | ឈើ លេខ២ | ឈើលេខ៣ និង ក្រៅលំដាប់ |
|---|---|---|---|---|---|---|---|---|---|
| | | ក្រញូង | ក្រាក់ក្រញូង | បេង | នាងនួន | ធ្នង់ | | | |
| ១ | សៀមរាប | ៥ ៤៦០ ០០០ | ២ ១០០ ០០០ | ២ ៥២០ ០០០ | ២ ៥២០ ០០០ | ២ ១០០ ០០០ | ១ ១៧៦ ០០០ | ១ ០៥០ ០០០ | ៦៣០ ០០០ |
| ២ | បន្ទាយមានជ័យ | ៥ ៤៦០ ០០០ | ២ ១០០ ០០០ | ២ ៥២០ ០០០ | ២ ៥២០ ០០០ | ២ ១០០ ០០០ | ១ ២៦០ ០០០ | ១ ១៣៤ ០០០ | ៦៣០ ០០០ |
| ៣ | ឧត្តរមានជ័យ | ៥ ០៤០ ០០០ | ១ ៦៨០ ០០០ | ២ ១០០ ០០០ | ២ ១០០ ០០០ | ១ ៦៨០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៦៣០ ០០០ |
| ៤ | ព្រះវិហារ | ៥ ០៤០ ០០០ | ១ ៦៨០ ០០០ | ២ ១០០ ០០០ | ២ ១០០ ០០០ | ១ ៦៨០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៦៣០ ០០០ |
| ៥ | កំពង់ធំ | ៥ ៤៦០ ០០០ | ២ ១០០ ០០០ | ២ ៥២០ ០០០ | ២ ៥២០ ០០០ | ២ ១០០ ០០០ | ១ ១៧៦ ០០០ | ១ ០៥០ ០០០ | ៦៣០ ០០០ |
| ៦ | ស្វាយរៀង | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ៣ ៣៦០ ០០០ | ៣ ៣៦០ ០០០ | ២ ៩៤០ ០០០ | ១ ៣០២ ០០០ | ១ ១៧៦ ០០០ | ៨៤០ ០០០ |
| ៧ | ព្រៃវែង | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ៣ ៣៦០ ០០០ | ៣ ៣៦០ ០០០ | ២ ៩៤០ ០០០ | ១ ២១៨ ០០០ | ១ ១៧៦ ០០០ | ៨៤០ ០០០ |
| ៨ | កំពង់ចាម | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ៣ ៧៨០ ០០០ | ៣ ៧៨០ ០០០ | ២ ៩៤០ ០០០ | ១ ១៣៤ ០០០ | ១ ០៥០ ០០០ | ៧១៤ ០០០ |
| ៩ | ក្រចេះ | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ១០០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៦៣០ ០០០ |
| ១០ | ស្ទឹងត្រែង | ៥ ៤៦០ ០០០ | ២ ១០០ ០០០ | ២ ៥២០ ០០០ | ២ ៥២០ ០០០ | ១ ៦៨០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៦៣០ ០០០ |
| ១១ | រតនគិរី | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ២ ៥២០ ០០០ | ២ ៥២០ ០០០ | ២ ១០០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៦៣០ ០០០ |
| ១២ | មណ្ឌលគិរី | ៥ ៨៨០ ០០០ | ២ ៥២០ ០០០ | ២ ១០០ ០០០ | ២ ១០០ ០០០ | ១ ៦៨០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៦៣០ ០០០ |
| ១៣ | កណ្តាល | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ៤ ២០០ ០០០ | ៤ ២០០ ០០០ | ៣ ៧៨០ ០០០ | ១ ៥១២ ០០០ | ១ ៣៨៦ ០០០ | ១ ០៥០ ០០០ |
| ១៤ | ភ្នំពេញ | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ៤ ២០០ ០០០ | ៤ ២០០ ០០០ | ៣ ៧៨០ ០០០ | ១ ៥១២ ០០០ | ១ ៣៨៦ ០០០ | ១ ០៥០ ០០០ |
| ១៥ | កំពង់ស្ពឺ | ៥ ៤៦០ ០០០ | ២ ១០០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ៥២០ ០០០ | ១ ១៧៦ ០០០ | ១ ០៥០ ០០០ | ៦៣០ ០០០ |
| ១៦ | កំពង់ឆ្នាំង | ៥ ៤៦០ ០០០ | ២ ១០០ ០០០ | ៣ ៣៦០ ០០០ | ៣ ៣៦០ ០០០ | ២ ៩៤០ ០០០ | ១ ២៦០ ០០០ | ១ ១៣៤ ០០០ | ៨៤០ ០០០ |
| ១៧ | ពោធិសាត់ | ៥ ០៤០ ០០០ | ១ ៦៨០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ៥២០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៦៣០·០០០ |
| ១៨ | បាត់ដំបង | ៥ ៤៦០ ០០០ | ២ ១០០ ០០០ | ៣ ៣៦០ ០០០ | ៣ ៣៦០ ០០០ | ២ ៩៤០ ០០០ | ១ ២៦០ ០០០ | ១ ១៧៦ ០០០ | ៨៤០ ០០០ |
| ១៩ | ប៉ៃលិន | ៥ ៤៦០ ០០០ | ២ ១០០ ០០០ | ២ ៥២០ ០០០ | ២ ៥២០ ០០០ | ២ ១០០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៨៤០ ០០០ |
| ២០ | កំពត | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ៥២០ ០០០ | ១ ៤៧០ ០០០ | ១ ៣៤៤ ០០០ | ១ ០៥០ ០០០ |
| ២១ | តាកែវ | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ៣ ៣៦០ ០០០ | ៣ ៣៦០ ០០០ | ២ ៩៤០ ០០០ | ១ ៥៩៦ ០០០ | ១ ៤៧០ ០០០ | ១ ០៥០ ០០០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២២ | កែប | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ៥២០ ០០០ | ១ ៥៩៦ ០០០ | ១ ៤៧០ ០០០ | ៩៦៦ ០០០ |
| ២៣ | ព្រះសីហនុ | ៦ ៣០០ ០០០ | ២ ៩៤០ ០០០ | ៣ ៣៦០ ០០០ | ៣ ៣៦០ ០០០ | ២ ៩៤០ ០០០ | ១ ៤៧០ ០០០ | ១ ៣៤៤ ០០០ | ៩៦៦ ០០០ |
| ២៤ | កោះកុង | ៥ ០៤០ ០០០ | ២ ៥២០ ០០០ | ២ ៩៤០ ០០០ | ២ ៩៤០ ០០០ | ២ ៥២០ ០០០ | ១ ០៥០ ០០០ | ៩២៤ ០០០ | ៦៣០ ០០០ |

**ប្រការ ២ :** រាល់តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើដទៃទៀត ដែលពុំមានចែងក្នុងប្រការ ១ ខាងលើ នឹងត្រូវកំណត់តម្លៃជាក្រោយ ។

**ប្រការ ៣ :** តម្លៃទីផ្សារជាមូលដ្ឋាននៃឈើជ្រុង ឈើអារ ដែលបានកំណត់ក្នុងប្រការ១ ខាងលើ នឹងធ្វើការពិនិត្យកែសម្រួលឡើងវិញជារៀងរាល់ឆ្នាំនៅខែឧសភា ហើយករណីចាំបាច់អាចត្រូវកំណត់ឡើងវិញ តាមតម្រូវការជាក់ស្តែង។

**ប្រការ ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥ :** អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៦ ខែ[illegible] ឆ្នាំ ២០១០

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ចាន់ សារុន

**កន្លែងទទួល:**

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- ដូចប្រការ ៥
- គ្រប់សាលាខេត្ត-រាជធានី
- ឯកសារ-កាលប្បវត្តិ